ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ៣៧៨៦ ព.ណ.ភ.ក

ថ្ងៃ...ខែ... ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ១២ ឆ្នាំ២០២០

## សេចក្ដីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បងប្អូនផលិតករ សិប្បករ អាជីវករ សហគ្រាសធុនតូច និងមធ្យមកម្ពុជា ដែលបានដាក់ពាក្យចូលរួមតាំងបង្ហាញផលិតផលខ្មែរ ក្នុងឱកាសយុទ្ធនាការទិញផលិតផលខ្មែរជុំកាលទី៥ ចាប់ពីថ្ងៃទី២៤-២៧ ខែធ្នូ ឆ្នាំ២០២០ នៅក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឲ្យបានជ្រាបថា៖ អនុវត្តតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចូលរួមទប់ស្កាត់នូវការរីករាលដាលនៃជំងឺកូវីដ-១៩ ឲ្យមានប្រសិទ្ធភាពនិងទាន់ពេលវេលា ក្រសួងពាណិជ្ជកម្មសូមប្រកាសលើកពេលរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ក្នុងខេត្តខាងលើរហូតដល់មានសេចក្ដីជូនដំណឹងជាថ្មី។

ចំពោះព័ត៌មានលម្អិត សូមទាក់ទងនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ដែលមានទីតាំងស្ថិតនៅជាន់ទីពីរ នៃអាគារទីស្ដីការក្រសួងពាណិជ្ជកម្ម អាសយដ្ឋាន៖ ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

| | |
|---|---|
| ទូរស័ព្ទទាក់ទង៖ | ០៧៨ ៧៥៥ ៥៥១ ឬ ០៧៧ ៣៣៩ ៤៣៩ ឬ ០៧៧ ៣៣២ ២៣៣ ឬ ០១៧ ៤៥៥ ០៥១ |
| អាសយដ្ឋានអ៊ីមែល៖ | ritatong19@gmail.com ឬ neary86@gmail.com ឬ vuthakep@yahoo.com ឬ kdi_mpp@yahoo.com |

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងពាណិជ្ជកម្ម